# សេចក្តីប្រកាសពត៌មាន

សាលាក្រុងឡុងប៊ីឆ
ការិយាល័យពត៌មានសាធារណៈ
411 W. Ocean Blvd,
Long Beach, CA 90802

**4/5/2020**

សំរាប់ផ្សព្វផ្សាយបន្ទាន់

សេចក្តីប្រកាសពត៌មាន # 040520

**ប្រធានបទ:** **ក្នុងកំឡុងពេលជំងឺរាតត្បាត COVID-19 ឆ្មា និងឆ្កែចំនួនច្រើនជាង ១៧០ ក្បាលនៅក្នុងជំរកថែទាំសត្វ ស្វែងរកផ្ទះ**

**ទំនាក់ទំនង:** មជ្ឈមណ្ឌលពត៌មានរួម សាលាក្រុងឡុងប៊ីឆ
562.570.NEWS
jic@longbeach.gov



ក្រុងឡុងប៊ីឆ, រដ្ឋកាលីហ្វ័រញ៉ា - Rufus គឺជាឆ្កែសប្បាយ សង្ហារមួយក្បាល ដែលមានអាយុ ៨ ឆ្នាំ កូនកាត់ Pit Bull-Shar Pei ដែលចូលចិត្តស្វាគមន៍ផ្តល់ហែហ្វាយ ដោយក្រញ៉ាំជើងរបស់វា។ បន្ទាប់ពី ៨ ខែ នៅជាមួយសេវាថែទាំសត្វក្រុងឡុងប៊ីឆ Long Beach Animal Care Services (ACS), Rufus ឥឡូវនេះ គឺជាឆ្កែមួយក្បាល ក្នុងចំណោមឆ្កែ ៦៩ និងឆ្មា ១០៣ ក្បាលផ្សេងទៀត ដែលថ្មីៗនេះ បានយកទៅចិញ្ចឹម ឬយកមកចិញ្ចឹមបន្ត (យកមកធ្វើជារបស់ខ្លួន) ចូលទៅក្នុងផ្ទះពី ACS តាំងពីថ្ងៃទី១៣ ខែមិនា ក្នុងកំឡុងពេលជំងឺរាតត្បាត COVID-19។

គឺគិតត្រឹមថ្ងៃសុក្រ ទី៣ ខែមេសានេះ មានតែឆ្កែ៦ ក្បាល និងឆ្មា៨ ក្បាលតែប៉ុណ្ណោះ នៅក្នុងទីជំរក។ សត្វផ្សេងទៀតដែលនៅសេសសល់ គឺបានត្រៀមខ្លួនរួចរាល់ជាស្រេច ដើម្បីទៅរស់នៅផ្ទះចិញ្ចឹម ឬកំពុងស្ថិតនៅក្នុងការថែទាំវេជ្ជសាស្ត្រ ឬឥរិយាបទ ឬការសង្កេតមើល។

អភិបាលក្រុង Robert Garcia មានប្រសាសន៍ថា “ក្រុមសេវាថែទាំសត្វរបស់យើង និងអ្នកស្ម័គ្រចិត្តដ៏អស្ចារ្យទាំងឡាយរបស់យើង និងក្រុមសង្គ្រោះ កំពុងធ្វើការងារដែលមិនគួរអោយជឿក្នុងកំឡុងវិបត្តិសុខភាពនេះ ដោយធ្វើការលើកទឹកចិត្តដល់មនុស្សទាំងអស់ ដើម្បីធ្វើការចិញ្ចឹមផ្តល់ជំរកអោយសត្វ ដោយការធ្វើដូច្នោះគឺជួយសង្គ្រោះជីវិត ដល់សត្វជាច្រើនក្បាល,”។ “ក្នុងកំឡុងពេលស្ត្រេស ឬតានតឹងផ្លូវចិត្តនេះ ការចិញ្ចឹមបន្ត ឬការយកមកចិញ្ចឹមធ្វើជារបស់ខ្លួន នូវសត្វចិញ្ចឹមផងដែរ អាចផ្តល់នូវសេចក្តីសុខយ៉ាងខ្លាំងក្រៃលែង”។

មនុស្សទាំងឡាយណាដែលយកទៅចិញ្ចឹមបន្ត (បណ្តោះអាសន្ន) យល់ព្រមទទួលយកសត្វទាំងនោះ ទៅផ្ទះរបស់ពួកគាត់ និងផ្តល់សេចក្តីស្រឡាញ់ ថែទាំរក្សា និងការយកចិត្តទុកដាក់អោយពួកគេ ទាំងការដែលបានកំណត់ពេលទុកជាមុន ឬរហូតដល់ពេលដែលសត្វនោះក្លាយមកជារបស់ខ្លួនដែលទុកចិញ្ចឹមរហូត។ ការចិញ្ចឹមសត្វមួយរយៈ ផ្តល់អោយពួកគាត់នូវពេលវេលាច្រើន ដែលសត្វនោះនិងអាចត្រូវជ្រើសរើសយកទៅចិញ្ចឹមបាន ជួយអោយសត្វមានទំនាក់ទំនងក្នុងសង្គម និងជួយអោយស្គាល់សត្វនោះអោយបានប្រសើរ ដើម្បីដាក់សត្វនោះអាចត្រូវបានយកទៅដាក់ នៅក្នុងផ្ទះដែលប្រសើរបំផុតជារៀងរហូតតាមតែអាចធ្វើទៅបាន។ ការចិញ្ចឹម គឺមានប្រយោជន៍ ជាពិសេស ក្នុងកំឡុងពេលជំងឺរាតត្បាត ដោយសារថាបច្ចុប្បន្ននេះ ACS មានអ្នកស្ម័គ្រចិត្តតិចតួចណាស់ប្រចាំការ នៅទីតាំង។

Staycee Dains អ្នកគ្រប់គ្រងសេវាថែទាំសត្វក្រុងឡុងប៊ីឆ មានប្រសាសន៍ថា “ដោយប្រជាពលរដ្ឋនៅក្នុងក្រុងឡុងប៊ីឆ អនុវត្តតាមសណ្តាប់ធ្នាប់ ‘មានសុវត្ថិភាពជាង ពេលនៅផ្ទះ’ ក្នុងការបញ្ឈប់ការរីករាលដាលនៃមេរោគ COVID-19 យើងបានទទួលស្គាល់នូវឱកាសដ៏ធំធេង សំរាប់ប្រជាពលរដ្ឋទាំងឡាយក្នុងការផ្តល់ទីជំរកចិញ្ចឹមសត្វ,”។ “សហគមន៍កំពុងបន្តធ្វើការងារបានល្អ ដោយមិនយកសត្វនានាមកអោយយើងនោះទេ លើកលែងតែសត្វដែលឈឺធ្ងន់ ឬមានរបួសធ្ងន់ ឬកំពុងរងគ្រោះ។ ហេតុការណ៍ដែលសុនខាគារ ឬជំរកឆ្កែរបស់យើងនៅទទេ ដែលមិនធ្លាប់មានពីមុនមកនោះឡើយ ហើយយើងសូមថ្លែងអំណរគុណដល់បុគ្គលិកនូវកិច្ចប្រឹងប្រែងធ្វើការយ៉ាងខ្លាំងខ្លា និងមិនចេះនឿយហត់ និងដៃគូរសង្គ្រោះនានា និងសហគមន៍របស់យើង”។

Rufus បានមកកាន់ទីជម្រកក្នុងខែសីហា ឆ្នាំ២០១៩។ វារងគ្រោះដោយសារលក្ខ័ណ្ឌនៃជំងឺស្បែក ដែលបង្ហាញអោយឃើញថា ស្បែកវាស្ងួត ហើយស្ទើង។ ក្រុមវេជ្ជសាស្ត្រ ACS បានធ្វើការព្យាបាលលក្ខ័ណ្ឌរបស់វា ហើយភ្លាមៗនោះ Rufus ក្លាយមកជាអ្នកចូលចិត្តទីជំរកនៅក្នុងចំណោមបុគ្គលិក និងអ្នកស្ម័គ្រចិត្តទាំងឡាយ ដោយសារវាមានសេចក្តីសុភាពរាបសារ និងចិត្តល្អ។ នៅថ្ងៃទី២០ ខែមីនា Rufus បានត្រូវដាក់ចូលទៅក្នុងកន្លែងចិញ្ចឹម ហើយប្រាំថ្ងៃក្រោយមកបានរកឃើញនូវផ្ទះអមតៈ ឬផ្ទះជារៀងរហូតរបស់វា ជាមួយនិងគ្រួសារមួយមកពីក្រុងស្តុកតុន នៅរដ្ឋកាលីហ្វ័រញ៉ាភាគខាងជើង។ ពួកគេមានអារម្មណ៍ទាក់ទាញក្នុងការធ្វើដំណើរមក និងយកវាទៅចិញ្ចឹម បន្ទាប់ពីមើលឃើញរូបថតរបស់វា លើវេបសាយឈ្មោះ Live Love Animal Rescue.

រហូតដល់មានការផ្តល់ដំណឹងនាពេលខាងមុខ ACS បើកបំរើការ តាមការណាត់ជួបតែប៉ុណ្ណោះ។ មន្ត្រីគ្រប់គ្រងសត្វទាំងឡាយ បន្តទទួលយក ឬដោះស្រាយចំពោះបញ្ហាលេចធ្លោបំផុត និងបញ្ហាសុវត្ថិភាពសាធារណៈ នៅក្នុងសហគមន៍។ ការផ្តល់អាជ្ញាប័ណ្ណសត្វចិញ្ចឹម

អាចធ្វើបានតាមរយៈប្រៃសនីយ៍ ដោយផ្ញើការទូទាត់ទៅកាន់អាស័យដ្ឋាន 7700 E. Spring St. Long Beach, CA 90815, តាមទូរស័ព្ទ ដោយទូរស័ព្ទទៅលេខ 562-570- 3081, ឬតាមអនឡាយ ឯ www.longbeachanimalcare.com.

សំរាប់សេវាយកទៅចិញ្ចឹម សាធារណៈជនអាចអ៊ីម៉ែលមកកាន់ AnimalRescue@longbeach.gov។ សំរាប់ការលះបង់ ឬការឈប់ចិញ្ចឹមនូវសត្វឈឺ ឬសត្វរបួសទាំងឡាយ ឬដើម្បីធ្វើអោយជួបជុំគ្នាវិញនូវសត្វណាមួយ ជាមួយនិងម្ចាស់របស់វាវិញ, សូមទូរស័ព្ទទៅលេខ 562-570-7387។ សំរាប់សំណួរផ្សេងៗ, អ៊ីម៉ែលទៅកាន់ AnimalRescue@longbeach.gov។

សំរាប់ពត៌មានថ្មីៗបំផុតស្តីអំពីជំងឺ COVID-19, ជាមួយនិងពត៌មានពិស្តារទាំងឡាយ ដែលសាលាក្រុងឡុងប៊ីឆកំពុងតែធ្វើ ដើម្បីរក្សានូវប្រជាពលរដ្ឋទាំងអស់របស់ខ្លួន អោយមានសុវត្ថិភាព, ទស្សនា www.longbeach.gov/COVID19 និងតាមមើល @LongBeachCity លើ Facebook, Twitter និង Instagram.

---

សំរាប់ពត៌មាន, រូបភាព, វីឌីអូ និងសេចក្តីប្រកាសនានាបន្ថែមទៀត នៃអ្វីដែលកំពុងកើតឡើងក្នុងក្រុងឡុងប៊ីឆ តាមមើលពួកយើង លើ Facebook, Twitter, Instagram និង YouTube.